អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
**Civil Party Lead Co-Lawyers' Section**
**Section des co-avocats principaux pour les parties civiles**

**ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-May-2019, 13:40
CMS/CFO: Sann Rada

**ជូនចំពោះ៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**
**លោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង**
**ភាគីទាំងអស់ក្នុងសំណុំរឿង ០០២**

**ពី៖** **លោក ពេជ អង្គ និង លោកស្រី Marie Guiraud**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**កម្មវត្ថុ៖** **មតិយោបល់ និងការជំទាស់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ ដែលស្នើសុំឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញ ជាឯកសារសាធារណៈ"**

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ ក្នុងអំឡុងពេលនៃសវនាការសាធារណៈមួយ[១]។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ សាលក្រមដែលមានសំអាងហេតុពេញលេញត្រូវបានជូនដំណឹងដល់ភាគីជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង[២]។ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈអន្តរការិយាល័យមួយ ("អនុស្សរណៈ") ដោយស្នើឲ្យភាគីទាំងអស់ផ្តល់មតិយោបល់អំពីវិធានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈ នូវឯកសារសម្ងាត់ចំនួន ១.៤៣៩ "ដែលត្រូវបានយកមកធ្វើជាសំអាង យោង ឬដកស្រង់នៅក្នុង

[១] *សូមមើល* ឯកសារ **E1/529.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[២] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (សាលក្រមដែលមានសំអាងហេតុពេញលេញដែលបានជូនដំណឹងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩)។

សាលក្រម" នៅត្រឹមថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩[៣]។ តទៅនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមផ្តល់មតិយោបល់ និងការជំទាស់របស់ខ្លួនទៅនឹងឯកសារមួយចំនួន ដែលពាក់ព័ន្ធចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

***ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក***

២. សហមេធាវីនាំមុខមិនជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទជាសាធារណៈចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទព័ត៌មានបន្ថែមដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក ទេ ដោយសារឯកសារទាំងនេះស្ថិតក្រោមបញ្ញត្តិនៃមាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្តដែលចែងថា "ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់ម្ចាស់បណ្តឹង និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងទម្រង់បែបបទព័ត៌មានរបស់ជនរងគ្រោះ ហើយដែលក្លាយជាសាធារណៈ អនុលោមតាមមាត្រា ៤ ត្រូវកោសលុបចេញពីឯកសារដែលយកមកដាក់ក្នុងគេហទំព័ររបស់ អ.វ.ត.ក"។

***ឧបសម្ព័ន្ធអំពីសំណងដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ខ គួរត្រូវរក្សាជាឯកសារសម្ងាត់ដដែល***

៣. សហមេធាវីនាំមុខជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទជាសាធារណៈ ចំពោះឧបសម្ព័ន្ធសម្ងាត់នៃបណ្តឹងទាមទារសំណងចុងក្រោយរបស់ខ្លួន (ឯកសារ E457/6/2) និងសេចក្តីសន្និដ្ឋានបន្ថែមស្តីពីបញ្ហាមូលនិធិពាក់ព័ន្ធនឹងគម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើសុំគោលការណ៍ណែនាំ (ឯកសារ E457/6/2/4) ដូចបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ខ នៃអនុស្សរណៈ[៤]។ សហមេធាវីនាំមុខសូមរម្លឹកថា ការអនុវត្តន៍នៃការដាក់ឧបសម្ព័ន្ធពាក់ព័ន្ធនឹងសំណងជាសម្ងាត់ ត្រូវបានបង្កើតឡើងនៅក្នុងសំណុំរឿង ០០២/០១ ហើយបញ្ជីឧបសម្ព័ន្ធទាំងនោះនៅតែជាឯកសារសម្ងាត់ដដែល ទោះបីត្រូវបានដកស្រង់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ក៏ដោយ។ សហមេធាវី

[៣] ឯកសារ **E467** អនុស្សរណៈអន្តរការិយាល័យមានចំណងជើងថា "ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ ដែលស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៦ ("អនុស្សរណៈ")។

[៤] ឯកសារ **E467.2** ឧបសម្ព័ន្ធ ខ៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងការដាក់ឯកសារនានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ERN 01614788-89 ដែលរៀបរាប់នូវឯកសារ E457/6/2/1.1.1, E457/6/2/1.1.2, E457/6/2/1.1.3, E457/6/2/1.1.4, E457/6/2/1.1.5, E457/6/2/1.1.6, E457/6/2/1.1.7, E457/6/2/1.1.8, E457/6/2/1.1.9, E457/6/2/1.1.10, E457/6/2/1.1.11, E457/6/2/1.1.12, E457/6/2/1.1.13, E457/6/2/1.1.15, E457/6/2/4.2, E457/6/2/4.3 សម្រាប់ការស្នើសុំធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ។

នាំមុខយល់ឃើញថា ពុំមានសំអាងហេតុណាមួយដែលត្រូវងាកចេញពីការអនុវត្តនេះឡើយ។ លើកលែងតែលិខិតប្រាស្រ័យទាក់ទងរវាងសហមេធាវីនាំមុខ អង្គភាពគាំពារជនរងគ្រោះ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូគម្រោង ព័ត៌មានដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ គឺត្រូវបានបំពេញដោយភាគីទីបី ដែលមិនត្រូវបានជូនដំណឹងថា ព័ត៌មានទាំងនោះ នឹងត្រូវបានដាក់បង្ហាញជាសាធារណៈឡើយ ផ្អែកតាមការអនុវត្តនៅក្នុងសំណុំរឿង ០០២/០១[៥] ។ ឧបសម្ព័ន្ធនៃសំណងត្រូវបានដាក់ជាឯកសារសម្ងាត់ក្នុងគោលបំណងល្អ ដោយសារឯកសារទាំងនោះមាន ឧទាហរណ៍៖ ការរៀបរាប់លម្អិតអំពីគម្រោងថវិកា នៅក្នុងករណីភាគច្រើន រួមទាំង ព័ត៌មានអំពីប្រាក់បៀវត្សរ៍ និងការចំណាយក្នុងការរៀបចំគម្រោង

អត្តសញ្ញាណរបស់មន្ត្រីគម្រោង កិច្ចសន្យាការងាររវាងភាគីទីបី កិច្ចព្រមព្រៀងរវាងភាគីទីបី ព័ត៌មានទំនាក់ទំនងសម្រាប់ម្ចាស់ជំនួយ និងដៃគូគម្រោង និងក្នុងករណីមួយចំនួន ព័ត៌មានស្ដីពីគណនេយ្យធនាគារដែលមាននៅក្នុងកិច្ចព្រមព្រៀងហិរញ្ញវត្ថុ។ ទោះបីសហមេធាវីនាំមុខគោរពដល់គោលការណ៍តម្លាភាពនៃកិច្ចដំណើរការនីតិវិធីក៏ដោយ តែមិនមែនជាការសមរម្យទេដែលធ្វើចំណាត់ប្រភេទជាសាធារណៈចំពោះឯកសារដែលពាក់ព័ន្ធនឹងសំណង ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់នោះ។

### *ឯកសារនានាដែលមាននៅក្នុងឧបសម្ព័ន្ធ ខ*

៤. សហមេធាវីនាំមុខមិនជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ ចំពោះឯកសារ E344 ទេ តែសូមជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ ចំពោះឯកសារ E344.1 ដោយសារឯកសារនេះមានលេខទូរសព្ទរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខមិនជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ ចំពោះសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលបានកែប្រែរបស់ខ្លួនទេ។

---

[៥] ឯកសារ **E457/6/2** បណ្ដឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណងនៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ១៤ និងជើងទំព័រ ២២។

***ឯកសារនានាពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានដកខ្លួន ដែលមាននៅក្នុងឧបសម្ព័ន្ធឃ***

៥. សហមេធាវីនាំមុខ ពុំមានការសង្កេតជាក់លាក់ទាក់ទិននឹងឯកសារនានាដែលបានរៀបរាប់នៅក្នុង ឧបសម្ព័ន្ធ ឃ ដែលទាក់ទិននឹងជនរងគ្រោះពីររូបដែលបានដកខ្លួនចេញពីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ ទេ។

សូមលោក/លោកស្រីចៅក្រមមេត្តាទទួលយកឯកសារនេះដោយគោរព។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩

| | |
|---|---|
| **ពេជ អង្គ** | **Marie Guiraud** |
| សហមេធាវីជាតិនាំមុខ | សហមេធាវីអន្តរជាតិនាំមុខ |